# ៧.រឿង ប្រាសាទបន្ទាយឆ្មារ

ប្រាសាទបន្ទាយឆ្មារ ស្ថិតនៅក្នុងឃុំបន្ទាយឆ្មារ ស្រុកបន្ទាយឆ្មារ ខេត្តបាត់ដំបង នៅចម្ងាយផ្លូវប្រមាណ ១២០ គ.ម. ទិសខាងជើងនៃក្រុងបាត់ដំបង ។ ពីដើមមក តំបន់នេះ ស្ថិតនៅក្នុងអាថិកំបាំងណាស់ ព្រោះផ្លូវទៅមក ជាផ្លូវរទេះ រថយន្តពុំអាចធ្វើដំណើរបានឡើយ មានតែអ្នកស្រាវជ្រាវខ្លះៗ ដែលខិតខំតស៊ូ ធ្វើដំណើរឲ្យបានទៅដល់ទីនោះ តែទៅបានដោយលំបាក គឺត្រូវប្រើរទេះគោ ឬ ជិះសេះ ។

នៅគ្រាសព្វថ្ងៃ, ទីតំបន់នេះ ក៏បានពង្រីកមុខមាត់ស្រស់បស់ដែរ ក្រោមការរៀបចំនៃរដ្ឋាភិបាលសង្គមរាស្រ្តនិយម ដែលមានសម្តេចឪទ្រង់ដឹកនាំ គឺរាជការបានចែកតំបន់នេះជាស្រុកមួយ ហៅថា ស្រុកបន្ទាយឆ្មារ ដែលពីដើម នៅជាឃុំតូច ស្ថិតនៅដាច់ស្រយាល ។ ទីកន្លែងនេះ រាប់បានថាជាភូមិភាគព្រៃភ្នំ ព្រោះនៅចម្ងាយតែ ២៥ គ.ម. ប៉ុណ្ណោះ ពីជើងភ្នំដងរែក ។

ការស្រាវជ្រាវរកប្រវត្តិពង្សាវតារ និង រឿងព្រេង ដែលទាក់ទងដោយប្រាសាទបុរាណនេះ ឃើញមាននៅរដាច់រដោច តាមសាស្រ្តាស្លឹករឹតខ្លះ តាមមាត់អ្នកស្រុកខ្លះ ។ យើងលើកយកមកពោលក្នុងទីនេះ តាមឯកសារក្រុមជំនុំទំនៀមទម្លាប់ ដែលសមាជិកខេត្តក្រៅសរសេរមកខ្លះ តាមសាស្រ្តាស្លឹករឹតនៅវត្តថ្មពួក ខ្លះ និងតាមសាស្រ្តាបុរាណ រឿងព្រះបាទយសកេរ ដែលមានតម្កល់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ខ្លះ ល្មមឲ្យប្រមូលសេចក្តីបាន ដូចតទៅនេះ ៖

មានសេចក្តីនិទានថា កាលពីអង្វែងព្រេងនាយឆ្ងាយមកហើយ មានក្សត្រមួយព្រះអង្គ គ្រងរាជ្យនៅចម្បាកបុរី (ត្រង់បន្ទាយឆ្មារសព្វថ្ងៃ) មានព្រះនាមថាព្រះបាទ "យសកេរ" ។ ព្រះអង្គមានព្រះទ័យសន្តោសមេត្តាណាស់, នគរជិតខាង ក៏ព្រះអង្គមិនដែលទ្រង់មានហេតុអ្វី ជាមួយឡើយ ។ ប្រជានុរាស្រ្តរបស់ព្រះអង្គ ក៏បានក្សេមក្សាន្តសន្តិភាពយ៉ាងរៀបរយ ។ ព្រះកិត្តិនាមដ៏ខ្ពង់ខ្ពស់នេះ បានលេចឮដំណឹងទៅដល់ព្រះរាជាមួយព្រះអង្គទៀត ព្រះនាមព្រះបាទ ហ៊្វលូ ដែលគ្រងរាជ្យនៅប្រាសាទព្រៅ នាំឲ្យចង់រំលោភអំណាចមកលើដែនចម្បាកបុរី ទើបថ្លែងសារមួយ ទារយករាជសម្បត្តិពីព្រះបាទយសកេរ ។ ដោយព្រះអង្គសព្វព្រះទ័យតែងនឹងការស្ងប់សន្តិភាព ព្រះបាទយសកេរ ទ្រង់ពុំព្រមតសង្គ្រាមទេ គៀសព្រះអង្គចេញពីព្រះរាជវាំងឲ្យផុត កុំឲ្យកើតសឹកសង្គ្រាមបាន ព្រោះនាំឲ្យលំបាកដល់ប្រជាពលរដ្ឋព្រះអង្គ ។

ដូច្នេះ ចាប់តាំងពីពេលនោះមក បន្ទាយឆ្មារ ក្នុងដែនចម្បាកបុរី ត្រូវឋិតនៅក្នុងការឃុំគ្រងនៃព្រះបាទ ហ៊្វលូ រហូតមក ។ លុះពេលជាចំណោរតមក ព្រះបាទ ហ៊្វលូ មានបំណងចង់ពង្រីកទឹកដីថែមទៀតផង និងខ្លាចក្រែងព្រះមហាក្សត្រអង្គមុន មកដណ្តើមយកស្រុកវិញផង ព្រះអង្គក៏ប្រកាសដល់មហាជនថា ឥឡូវនេះ បើនរណាមួយ អាចយកការណ៍ឲ្យច្បាស់ ពីទីកន្លែងព្រះបាទយសកេរបាន ព្រះអង្គនឹងប្រទាននូវមាស ១០០០ តម្លឹង ។

ពេលនោះ មានពួកព្រានដែលដើរបាញ់ តាមព្រៃផ្សេងៗ ក៏ទៅលបមើលឃើញព្រះបាទយសកេរ ជាមួយព្រះនាងបទុម ជាអគ្គមហេសី និង រាជកុមារវិបុលកេរ ទ្រង់គង់នៅប្រាសាទតាមាន់ ដែលឋិតនៅលើខ្នងភ្នំដងរែក ។ ដោយសារចង់បានរង្វាន់ជាមាស ១០០០ តម្លឹងនោះ ពួកព្រានកំណាច នាំគ្នាលបចាប់ព្រះបាទយសកេរ នៅពេលដែលព្រះអង្គគង់ស្មឹងស្មាធិ៍ តែមួយអង្គឯងនៅក្នុងព្រៃស្ងាត់, នាំយកទៅថ្វាយព្រះបាទហ៊្វលូ ដើម្បីបើកយករង្វាន់ ។ ពេលនោះ ព្រះបាទហ៊្វលូ ក៏ទ្រង់ត្រាស់បញ្ជាឲ្យពេជ្ឈឃាដ នាំយកព្រះអង្គទៅដាក់ទោស, យ៉ាងទម្ងន់ ។

នឹងចាប់ថ្លែងពីព្រះនាងបទុម និង ព្រះរាជបុត្រាវិញម្តង ។ ព្រះនាងសោយសោកសង្រេងសង្រៃដោយបាត់ស្វាមី ហើយថែមទាំងបានទទួលដំណឹងថា ព្រះបាទហ៊្វលូ កំពុងតែដាក់ក្តីជាទម្ងន់ទៀត ។ ព្រះនាងរក្សាបុត្រាបណ្តូលហឫទ័យ នៅក្នុងព្រៃអស់រយៈវេលាយ៉ាងយូរ រហូតដល់ព្រះរាជបុត្រា មានព្រះជន្ម ១២ វស្សា ។ ព្រះកុមារ ដេញដោលពីរឿងរ៉ាវនៃព្រះបិតា, ឯព្រះនាងបទុម ជាមាតា ក៏រាយរាប់សព្វគ្រប់ប្រទានបុត្រស្តាប់ ។ តាំងពីជ្រាបរឿងហេតុនេះពិតមក ព្រះកុមារស្រីវិបុលកេរ តែងតែនឹករលឹកព្រះបិតា ចង់តែសងសឹកឲ្យឃើញទាន់ហន់តាមកំហឹង, តែព្រះមាតាចេះតែព្រមានរំលឹកដាស់តឿន ឲ្យបំភ្លេចរឿងនេះចោលទៅ ព្រោះយើងឥតគ្នីគ្នា នៅក្នុងព្រៃដូចនេះ គ្មានសង្ឃឹមនឹងបានវិលត្រឡប់ទៅកាន់ស្រុក រកខុសត្រូវវិញបានឡើយ ។ ទោះបីព្រះមាតា ឃាំងឃាត់យ៉ាងណាក្តី, ព្រះរាជកុមារ នៅតែពុំសុខព្រះទ័យឡើយ ពេលមួយព្រះអង្គលាព្រះមាតា ទៅស្វែងសព្វទិសទី រកស៊ើបដំណឹងព្រះបិតា ។ ការស្វែងនេះប្រព្រឹត្តទៅអស់ពេលដ៏យូរ ស្រាប់តែទៅប្រទះឃើញ នៅត្រង់ចន្លោះនៃបន្ទាយឆ្មារនូវក្បួនហែអ្នកទោសទៅសម្លាប់ ។ ព្រះរាជកុមារក្រឡេកទៅស្គាល់អ្នកទោសនេះជាក់ជាបិតាព្រះអង្គ, ទ្រង់ក៏ដែកពពួកហ្វូងមនុស្ស ឆ្ពោះទៅដល់ទីចំពោះព្រះភក្ត្រនៃព្រះបាទហ៊្វលូ ដែលកំពុងតែគង់ទតក្បួននេះដែរ ។ ព្រះរាជកុមារ មានព្រះបន្ទូលខ្លាំងៗ ថា ៖

- អ្នកទោសនេះ ជាបិតាខ្ញុំ លោកគ្មានទោសខុសអ្វីទេ ។ ការដែលបញ្ជូនទៅសម្លាប់នេះ គ្មានហេតុផលអ្វីជាសំអាងឡើយ, ដូច្នេះ សុំឲ្យលែងភ្លាម បើចង់សម្លាប់ណាស់ ខ្ញុំស៊ូឲ្យសម្លាប់ខ្លួនខ្ញុំជំនួសវិញ !

ព្រះបាទហ៊្វលូ ទ្រង់បានឮហើយ ក៏ភ្ញាក់យ៉ាងខ្លាំង ហើយត្រាស់សួរទៅវិញថា ៖

- អ្នកឯងមកពីណា បានជាហ៊ានមកនិយាយយ៉ាងនេះ ? យើងនឹងឲ្យសម្លាប់ចោលក្នុងរឿណរង្គឥឡូវនេះ រាជកុមារតបភ្លាមថា ៖

- ខ្ញុំជារាជបុត្រនៃព្រះបាទយសកេរ គឺអ្នកទោសនេះឯង ខ្ញុំមិនខ្លាចស្លាប់ ដោយសារអយុត្តិធម៌ដូច្នេះទេ ! ខ្ញុំហ៊ានស្លាប់ជំនួសបិតាខ្ញុំ ។ ព្រះបាទហ៊្វលូ ទ្រង់ត្រាស់ទៀតថា

- កុមារក្លាហាន ! អ្នកនេះ ពិតជាឪពុកអ្នកឬ ? បើដូច្នេះ អ្នកចូលមក យើងនឹងដាក់ក្តីលើរូបអ្នកវិញ !

រាជកុមារក្លាហាន ក៏យាងចូលទៅទទួលទោស ជំនួសព្រះបិតាមួយរំពេច ។ ពេលនោះ ព្រះបាទហ៊្វូលូ ត្រាស់បញ្ជាឲ្យពេជ្ឈឃាដប្រហារព្រះរាជកុមារ នៅចំមុខបណ្តាជន ដែលកំពុងតែមកអឺ្វអរ ដើម្បីទុកជាបម្រាមដល់ជនទូទៅ ។ អ្នកស្រុក ដែលឈរមើលទាំងប៉ុន្មាន សឹងផ្អើលឈូឆរដោយសារហេតុការណ៍ចម្លែកនេះ។ ភ័យរន្ធត់ នឹកអាសូររាជកុមារ ខ្លះស្ងប់ស្ងែងនឹងចិត្តក្លៀវក្លា របស់ព្រះរាជកុមារនេះ ។

ដោយអានុភាពកតញ្ញូតាធម៌របស់ព្រះអង្គ ចំពោះអ្នកដ៏មានគុណ ដាវដ៏មុតរបស់ពេជ្ឈឃាដ ប្រែត្រឡប់ជាម្ងរមុខអស់រលីង ជាហេតុអស្ចារ្យណាស់ ។ ព្រះបាទហ៊្វូលូ ទ្រង់ពិរោធយ៉ាងខ្លាំង ស្រែកសន្ធាប់ឲ្យពេជ្ឈឃាដប្តូរដាវខ្ទររមុខនោះចេញ យកដាវសំលៀងមុត ហើយចូលមកកាប់ម្តងទៀត ។ ជាច្រើនលើកច្រើនគ្រា ដាវនៅតែម្ងរមុខ ពុំបានមុតដាច់សាច់កុមារ សូម្បីបន្តិចឡើយ ។ ឃើញថា ចាញ់ចេះហើយ ព្រះបាទហ៊្វូលូ ឲ្យពេជ្ឈឃាដគរភ្នក់ភ្លើងនោះ យ៉ាងសន្ធៅ ហើយចាប់រាជកុមារ បោះទៅកណ្តាលភ្នក់ភ្លើងនោះ, ប៉ុន្តែឥតប្រយោជន៍ទៀត ភ្លើងប្រែជាត្រជាក់ល្ហឹម ឥតមានសៅហ្មង ដល់សាច់ឈាមព្រះអង្គកុមារបន្តិចឡើយ ។ ព្រះរាជកុមារ ទ្រង់ក្រោកចេញពីភ្នក់ភ្លើង ដោយព្រះភក្ត្រញញឹមប្រិមប្រិយ ឆ្ពោះទៅរកព្រះបាទហ៊្វូលូ និងអាណាប្រជានុរាស្ត្រទាំងអស់ ។ ធ្វើប៉ុណ្ណេះហើយ ក៏ពុំទាន់អស់ព្រះទ័យទៀត ព្រះបាទហ៊្វូលូ ត្រាស់បញ្ជាឲ្យអមាត្យនាំយកដំរីចម្បាំង ដែលកាចសាហាវមួយហ្វូង នាំមកឲ្យព្រេចព្រះរាជកុមារទៀត ។ ពួកហ្មបាន បំផាយហ្វូងដំរីយ៉ាងលឿនស្លៅ ចូលតម្រង់ព្រះរាជកុមារ, តែអស្ចារ្យណាស់ ដំរីទាំងអស់ លុតជង្គង់ស្មើគ្នា នៅចម្ងាយពីរជំហានពីមុខកុមារ ។ មិនតែប៉ុណ្ណោះ ដំរីច្បងនៅមុខគេ បានលើកត្រកងព្រះអង្គ យ៉ាងថ្នាក់ថ្នម ដាក់លើក្បាលខ្លួនថែមទៀត ។ ពេលនោះ អ្នកស្រុកទាំងអស់ ផ្អើលឆោឡោ ចូលទៅចោមរោមព្រះរាជកុមារ ថ្វាយវរវន្ទាគ្រប់ៗ គ្នា ។ ឃើញមហិទ្ធិឫទ្ធិព្រះរាជកុមារដូច្នោះ ព្រះបាទហ៊្វូលូ លួចគៀសព្រះអង្គចេញបាត់ពីហ្វូងមនុស្ស ដែលកំពុងតែជ្រួលច្របល់ ។ ម៉្លោះហើយ នៅពេលដែលអ្នកផងរួចពីការជ្រួលជ្រើមវិញ ស្រាប់តែរកស្តេចហ៊្វូលូមិនឃើញសោះ ក៏យល់ថា ព្រះអង្គគៀសចេញបំបាត់ដាន ដោយខ្លាចឫទ្ធិបារមីព្រះរាជកុមារវិបុលកេរ ដែលឃើញជាក់ស្តែងអស្ចារ្យយ៉ាងនេះ ។

បន្ទាប់មក ព្រះរាជកុមារវិបុលកេរ បាននាំព្រះបិតាគង់លើព្រះទីន័ងគជេន្ទ្រ យាងដំណើរទៅដល់ប្រាសាទតាមាន់លើភ្នំដងរែក រួបរួមសុខទុក្ខជាមួយព្រះនាងបទុមយ៉ាងសុខសាន្តទៅ ។ ប៉ុន្តែ មិនយូរប៉ុន្មាន ដោយសារគ្រាំគ្រាក្នុងទារុណកម្មផង ព្រះបាទយសកេរជាព្រះបិតា ក៏សុគតនៅទីនោះ ។ នៅពេលបន្ទាប់មក, ព្រះរាជកុមាររៀបចំថ្វាយព្រះភ្លើង បញ្ចុះព្រះធាតុ យ៉ាងស្រួលបួលក្នុងទីនោះឯង ។

នៅពេលបន្ទាប់មកទៀត អ្នកស្រុកបន្ទាយឆ្មារ មាននាម៉ឺនសព្វមុខមន្ត្រីជាអាទិ បាននាំគ្នារៀបក្បួន ទៅដង្ហែព្រះរាជកុមារវិបុលកេរ នាំយកមកអភិសេកជាក្សត្រពេញយស នៅវាំងបន្ទាយឆ្មារ, ឯព្រះនាងបទុម ក៏រស់នៅយ៉ាងសុខសាន្ត ជាមួយរាជបុត្ររហូតទៅ ។

រឿងព្រេងនេះ ប្រហែលគ្នានឹងរឿងព្រេងនៅភ្នំស្រីវិបុលកេរ្តិ៍ នៅខេត្តសៀមរាប ប្លែកគ្នាតែខាងចុង ដែលរឿងភ្នំស្រីវិបុលកេរ្តិ៍ នៅសៀមរាបថា ព្រះរាជកុមារនេះ និង ព្រះវរមាតាសុគតទៅវិញ ។ ប៉ុន្តែបើដេញដោលរកឲ្យ

ឆ្ងាយទៅទៀត គេឃើញរឿងនេះ មានក្នុងគម្ពីរ "បញ្ញាសជាតក" ដែលជាគម្ពីរបាលីតែងស្រុកអាយ នៅជ្រោយសុវណ្ណភូមិយើងនេះ ។ ដូច្នេះអ្នកស្រាវជ្រាវ អាចយល់បានពីរផ្លូវថា ៖

១- ទំនងជាអ្នកស្រុកខ្មែរយើង បានឃើញរឿងនេះ មាននៅក្នុងគម្ពីរបញ្ញាសជាតករួចហើយ ទើបគេស្រង់មកដំណាល ភ្ជាប់នឹងទីភ្នំនេះទៅ ។

២- ប្រហែលជាមានរឿងព្រេងបុរាណនេះ ជាប់ជិតដោយនឹងភ្នំនេះ ភ្នំនោះ រួចមកហើយ ទើបអ្នកប្រាជ្ញចេះភាសាបាលី នាំយកទៅតែងបញ្ចូលក្នុងបញ្ញាសជាតក ជាក្រោយ ។

មតិទី ២ នេះ សមច្រើនដែរ ព្រោះមានរឿងព្រេងប្រចាំភ្នំ ភូមិ ស្រុក យើងច្រើនណាស់ ដែលក្លាយទៅជារឿងក្នុងបញ្ញាសជាតក ដូចជារឿង វរវង្សសូរវង្ស (ជួរភ្នំគិរីរម្យសព្វថ្ងៃ), ភ្នំនាងកង្រី (នៅកំពង់ឆ្នាំង) ជាដើម ។

ចំពោះពាក្យថា "បន្ទាយឆ្មារ" នេះវិញ ក៏នាំឲ្យមានការដេញដោលសន្និកណាស់ដែរ ។ តាមការយល់របស់អ្នកស្រាវជ្រាវខ្លះ ថាបន្ទាយឆ្មារនេះបានន័យថា "បន្ទាយតូច" ឬ "វាំងតូច" ផ្ទុយគ្នាអំពីបន្ទាយធំ ឬ នគរធំ ។ មតិនេះ ឃើញថា សមហេតុផលដែរ ព្រោះតាមប្រវត្តិសាស្ត្រយើង ក៏ឃើញមានបន្ទាយធំជារាជធានី ដែលហៅថា "មហានគរ" ប្រែថា ក្រុងធំ ។ ដូច្នេះ កាលបើមានបង្កើតក្រុងមួយទៀតដែលតូចល្មម ឬ ជារាជធានីតូច ដែលសម្រាប់ស្ដេចអនុជ ឬ ស្ដេចត្រាញ់គង់នៅ, ក៏អ្នកស្រុកអាចសំគាល់ហៅទីនោះថា ក្រុងតូច ឬ បន្ទាយតូច ឬ បន្ទាយឆ្មារ ដូច្នេះក៏បានដែរ ។ ឯកន្លែងនេះ ពិតជាមានទីក្រុងចាស់ប្រាកដមែន ដូចជាការស្រាវជ្រាវ របស់លោកហ្គុសលីយេរ សរសេរថា មានទីប្រជុំជនមួយឈ្មោះ ក្បាលអន្សោង នៅចម្ងាយ ២ គ.ម. ពីទីនេះ ធ្លាប់មានមនុស្សរស់នៅដល់ទៅប្រមាណជា ២០០.០០០ នាក់ សុទ្ធតែជាពួកអ្នកមានមុខងារ មកកសាងប្រាសាទពីជំនាន់នោះ ។ ប៉ុន្តែ ដោយចំណោរតមក នៅតំបន់នោះ មានទឹកជំនន់ជន់លិច, មានកើតជំងឺដង្កាត់ច្រើន, ពួកអ្នកស្រុកទាំងនេះ ក៏រត់ទៅនៅឯទីឆ្ងាយ ពីនេះបន្តិចទៅវិញ ដែលល្មមរស់នៅបានស្រួល គឺទីរួមស្រុកសុរិន្ទ សព្វថ្ងៃនេះ ។ ហេតុនេះហើយបានជាសុរិន្ទ ឡើងទៅជាទីប្រជុំជនសំខាន់មួយតាំងពីគ្រានោះមក ។ មិនតែប៉ុណ្ណោះ តាមយោបល់លោក អៃម៉ូនិញេ ថា មកដល់ឆ្នាំ ១៨៨៤ ដែលខេត្តសុរិន្ទ បានទៅសៀមហើយ ក៏ចៅហ្វាយខេត្តនេះ នៅតែមានងារថា ៖ ពញាសុរិន្ទភក្ដីធីននគរបន្ទាយសេមារ ។ យោបល់នេះ ក៏បញ្ជាក់ថែមទៀតថា ពួកអ្នកស្រុកសុរិន្ទ មានដើមកំណើតពីបន្ទាយឆ្មារនេះមែន ។

តាមការស្រាវជ្រាវ របស់លោក សឺដែស បានបញ្ជាក់ថា ប្រាសាទបន្ទាយឆ្មារ កសាងឡើង ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័ន ទី ៧ គឺព្រះអង្គសាង ឧទ្ទិសចំពោះវិញ្ញាណក្ខន្ធ នៃព្រះរាជបុត្រាព្រះអង្គ ព្រះនាមស្រិន្ទកុមារ ព្រមទាំងអ្នករួមអាវុធរបស់ព្រះអង្គ ៤ នាក់ទៀត ដែលស្លាប់បាត់បង់ជីវិតនៅក្នុងសមរភូមិ នៅគ្រាប្រយុទ្ធជាមួយកងទ័ពចម្ប៉ា ដែលចូលមករុករាន ។ តែបើតាមឯកសារផ្សេងទៀត ថា ព្រះបាទជ័យវរ្ម័ន ទី ២ បានសាងក្នុងដើមសតវត្សទី ៩ ។

ដូច្នេះ សរុបសេចក្ដីទៅ តាមរឿងព្រេងក្ដី សិលាចារឹកក្ដី ក៏បង្ហាញបញ្ជាក់ថា ទីប្រាសាទបន្ទាយឆ្មារនេះ ជាទី

ប្រជុំជនចាស់ក្នុងសម័យអង្គរ ល្មមសមគួរតាមពាក្យអ្នកស្រុកហៅ តាមទម្លាប់ពាក្យជាន់នោះ ហៅថា "បន្ទាយឆ្មារ" ដែលបានន័យថា "វាំងតូច" ។ ឯរឿងព្រេងបន្ថែមលើរឿងរ៉ាវដ៏វែង ដូចបានរៀបរាប់មកខាងលើនេះ គ្រាន់តែជាការប្រឌិតយកទីកន្លែង ទៅភ្ជាប់ជាមួយអក្សរសាស្ត្រ ឲ្យបានន័យពីរោះពិសាតែប៉ុណ្ណោះ